ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៨/១២-រ៉ូ ស៊ីង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន រ៉ូ ស៊ីង**
អាសយដ្ឋាន ៖ ភូមិទួលសង្កែ សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៨៣០ ៩០១ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖
- លោក ជូ ចាន់ស័ក ប្រធានការិយាល័យវិវាទក្រុមហ៊ុន រ៉ូ ស៊ីង

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖- **សហព័ន្ធសហជីពមោទនភាពកម្មករខ្មែរ**
- **សហជីពមោទនភាពកម្មករខ្មែរប្រចាំក្រុមហ៊ុន រ៉ូ ស៊ីង**

អាសយដ្ឋាន ៖ ភូមិទួលសង្កែ សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៨៨ ៣៧៣ ៨០០០ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖ **អវត្តមាន**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥ ២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◈ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◈ Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃទឹកដោះគោចំនួន ៣០ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា អនុវត្តទៅតាមគោលការណ៍ចាស់ ។

២- នៅពេលកម្មករនិយោជិតធ្វើការថ្ងៃបុណ្យ និងថ្ងៃអាទិត្យ សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន ៤០០០ រៀល ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ ។

៣- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃស្នាក់នៅជូនកម្មករនិយោជិតក្នុងម្នាក់ៗចំនួន ១៥ដុល្លារក្នុងមួយខែ។ ដោយឡែកក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ ។

៤- សុំកុំឱ្យក្រុមហ៊ុនធ្វើការផ្លាស់ប្តូរកម្មករនិយោជិតពីផ្នែកមួយទៅផ្នែកមួយទៀត។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ការផ្លាស់ប្តូរ គឺជាសិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុនផ្នែកផលិតកម្ម ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០៥៤ កប/អក/វក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យតូទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់សហព័ន្ធសហជីពម្ចាស់ទន់ភាពកម្មករខ្មែរ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងាររួមនេះជាបន្ទាន់ និងធ្វើការផ្សះ

ផ្សាជាលើកចុងក្រោយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៨ ចំណុច លើការទាមទារចំនួន ១២ ចំណុច។ ចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន រ៉ូ ស៊ីង លេខ ០៥៤ កប/អក/ វក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីសហជីពមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ប៉ុន្តែសហព័ន្ធសហជីពមោទនភាពកម្មករខ្មែរមិនបានមកចូលរួមសវនាការ ហើយក៏មិនបានបញ្ជាក់ពីមូលហេតុត្រឹមត្រូវណាមួយ ដែលមិនបានមកចូលរួមសវនាការអាជ្ញាកណ្តាលដែរ គ្រាន់តែបញ្ជាក់ថា កម្មករនិយោជិតនៃក្រុមហ៊ុន រ៉ូ ស៊ីង មិនអាចមកចូលរួមសវនាការទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដំណើរការតាមនីតិវិធីចុះ។ ចំណែកឯភាគីនិយោជកវិញ បានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន រ៉ូ ស៊ីង លេខ ០៥៤ កប/អក/វក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន រ៉ូ ស៊ីង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៧៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖

មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ដោយសារសហព័ន្ធសហជីពមោទនភាពកម្មករខ្មែរ ដែលជាដើមបណ្ដឹងមិនបានចូលរួមសវនាការ។

## **ហេតុផលនៃសេចក្ដីសម្រេច**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា តើនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្ដាលដែរ ឬទេ?

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញសេចក្ដីបង្គាប់ "* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលដោយចេញសេចក្ដីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្ដាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្ដាលមុនពេលធ្វើសេចក្ដីសម្រេចរបស់ខ្លួន"* ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ឹម និង វេ ៣, លេខ ១៣៨/០៨-ម៉ាលីន និងលេខ ១១/១១-ជូន តិចថាយល៍ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបិទសំណុំរឿងបាន *"លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន "* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ

មន្ត្រីលេខាធិការដ្ឋានបានទំនាក់ទំនងទៅកាន់សហព័ន្ធសហជីពមោទនភាពកម្មករខ្មែរ ជូនដំណឹងពីសវនាការអាជ្ញាកណ្ដាល ប៉ុន្តែភាគីសហជីពបានបញ្ជាក់ថា មិនមកចូលរួមសវនាការទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ភាគីសហជីពពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

THE ARBITRATION COUNCIL

**លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា “*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*” នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់ ។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និង ដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ ភាគីសហជីពមិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីពមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ២១ ខាងលើនេះទេ ។ ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ។

**លក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅក្នុងករណីនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងតាមទូរស័ព្ទរំលឹកទៅភាគីនិយោជក និងភាគីសហជីពអំពីសវនាការអាជ្ញាកណ្តាល ប៉ុន្តែភាគីសហជីពបានឆ្លើយថា កម្មករនិយោជិតនៃក្រុមហ៊ុន វ៉ូ ស៊ីង មិនអាចមកចូលរួមសវនាការទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដំណើរការតាមនីតិវិធីចុះ ។ ចំណែកភាគីនិយោជកបានអញ្ជើញមកចូលរួមក្នុងសវនាការតាមកាលកំណត់ ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីពមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ ។ ដូច្នេះ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ ។

ដូច្នេះ ជាសរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ ។

ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីភាគីសហជីពដែលជាដើមបណ្តឹងមិនចូលរួមក្នុងដំណើរការអាជ្ញាកណ្តាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីបង្គាប់ដែរ ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីសហជីពធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិតដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ ។ ប៉ុន្តែភាគីសហជីពបានជ្រើសរើសការមិនចូលរួមសវនាការ និងបោះបង់ឱកាសក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្រការទាមទាររបស់ខ្លួនទៅវិញ ។ ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងរបស់ខ្លួន ។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ ភាគីសហជីពមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា សហព័ន្ធសហជីពមោទនភាពកម្មករខ្មែរបានបោះបង់ចោលបណ្តឹងរបស់ខ្លួន ។ សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ០៨/១២-រ៉ូ ស៊ីង នេះ ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

សម្រេចបិទសំណុំរឿងលេខ ០៨/១២-រ៉ូ ស៊ីង ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា ៖ ------------------------------------